ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានហិរញ្ញវត្ថុ

# សិក្ខាសាលា
# ស្ដីពី
# ការដាក់ឲ្យអនុវត្តប្រព័ន្ធគ្រោងថវិកាគ្រឹះស្ថានសិក្សាសាធារណៈ និងរបាយការណ៍ហិរញ្ញវត្ថុ តាមប្រព័ន្ធព័ត៌មានវិទ្យា ឆ្ពោះទៅការប្រើប្រាស់ប្រព័ន្ធ FMIS

Funded by:

# មាតិកា



1 ការណែនាំទូទៅអំពីប្រព័ន្ធគ្រោងថវិកាគ្រឹះស្ថានសិក្សាសាធារណៈ

2 ការបែងចែក File គ្រោងថវិកា

3 ការគ្រោងថវិកាដំណើរការសាលារបស់គ្រឹះស្ថានសាធារណៈ

4 ការគ្រោងថវិកាអាហារូបករណ៍ និងបង្គន់អនាម័យ

5 ការគ្រោងថវិការបស់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ

6 ការបូកសរុបគម្រោងថវិការបស់គ្រឹះស្ថានសាធារណៈ

7 ការអនុវត្តប្រព័ន្ធលើប្រព័ន្ធគ្រោងថវិកាគ្រឹះស្ថានសិក្សាសាធារណៈ

# ផ្នែកទី ១៖

# អំពីប្រព័ន្ធគ្រោងថវិកាគ្រឹះស្ថានសិក្សាសាធារណៈ

# តើអ្វីជាប្រព័ន្ធគ្រោងថវិកាគ្រឹះស្ថានសិក្សាសាធារណៈ?



ត្រូវបានរៀបចំឡើងដើម្បីជួយសម្រួលដល់ការគ្រោងថវិកាដំណើរការសាលារៀន គ្រោងថវិកាអាហារូបករណ៍ និង បង្គន់អនាម័យរបស់គ្រឹះស្ថានសិក្សាសាធារណៈ អោយមានភាពងាយស្រួល ត្រឹមត្រូវ និងដើម្បីឈានទៅប្រើប្រាស់ក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា Financial Management Information System (FMIS) នាពេលខាងមុខ។



# 1 អំពីប្រព័ន្ធគ្រោងថវិកាគ្រឹះស្ថានសិក្សាសាធារណៈ



មន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត

↑

ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ

↑

គ្រឹះស្ថានអប់រំសាធារណៈ

ក្នុងប្រព័ន្ធនេះតម្រូវអោយគ្រប់គ្រឹះស្ថានអប់រំសាធារណៈ ទាំងអស់ជាអ្នកគ្រោងដោយផ្ទាល់ ដោយមន្ទីរអប់រំជំនាញរាជធានី ខេត្ត ជាអ្នកផ្តល់ File ដល់ការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ ហើយការិយាល័យអប់រំ ជាអ្នកបែងចែក File ដល់គ្រឹះស្ថានអប់រំសាធារណៈ។

# អំពីប្រព័ន្ធគ្រោងថវិកាគ្រឹះស្ថានសិក្សាសាធារណៈ(ត)



❖ សម្រាប់មន្ទីររាជធានី ខេត្តទាំងអស់នឹងទទួលបាន កញ្ចប់ (Folder) ដែលមានឈ្មោះអក្សរ P (Province) ។

❖ ក្នុង Folder នីមួយៗ មានផ្ទុកនូវ Folder មួយឈ្មោះថា D ដែល D គឺជាស្រុក (District) និង File ឈ្មោះថា Total_SOB.xlsm ដែល File នោះគឺសម្រាប់បូកសរុបទូទាំងខេត្ត។



# អំពីប្រព័ន្ធគ្រោងថវិកាគ្រឹះស្ថានសិក្សាសាធារណៈ(ត)






<u>នៅក្នុង Folder D មាន 6 Folder និង 2 File</u>

- Folder 1៖ សម្រាប់សាលាមត្តេយ្យសិក្សា
- Folder 2៖ សម្រាប់សាលាបឋមសិក្សា
- Folder 3៖ សម្រាប់អនុវិទ្យាល័យ
- Folder 4៖ សម្រាប់វិទ្យាល័យ
- Folder 5៖ សម្រាប់អគាធនធាន
- Folder 6៖ សម្រាប់វិទ្យាល័យបច្ចេកទេស

- File District_Plan.xlsm៖ គឺសម្រាប់ការិយាល័យក្រុង ស្រុក ខណ្ឌ ដែលការិយាល័យអប់រំ អាចធ្វើការគ្រោងថវិកាក្នុងជំពូក ៦០ និង ៦១ ព្រមទាំងការគ្រោងថវិកាចុះពិនិត្យតាមដានការងារបច្ចេកទេសតាមសាលារៀនក្នុងរង្វង់ដែនដី ក្រុង ស្រុក ខណ្ឌ *(យោងលិខិត ៧៧៧៨ សហវ អថ)* ដែលមានកញ្ចប់រួមច្រើនបំផុតសរុប ២៤លានរៀល។
- File Total_Schools_and_District.xlsm៖ សម្រាប់បូកសរុបគម្រោងថវិកាសាលា និងគម្រោងថវិការបស់ការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ។

# អំពីប្រព័ន្ធគ្រោងថវិកាគ្រឹះស្ថានសិក្សាសាធារណៈ(ត)



P → D→1




នៅក្នុង Folder 1 តំណាងអប់រំកុមារតូចមាន 2 File៖

- File E.xlsm ៖ តំណាងសាលាមត្តេយ្យសិក្សាពី E1, E2, ..,En
- File Total.xlsm ៖ សម្រាប់បូកសរុបពី E1, E2,…….,En

P → D→2




នៅក្នុង Folder 2 តំណាងបឋមសិក្សាមាន 2 File៖

- File P.xlsm ៖ តំណាងសាលាបឋមសិក្សាពី P1, P2,….,Pn
- File Total.xlsm ៖ សម្រាប់បូកសរុបពី P1, P2,…….,Pn

n គឺជាចំនួនសាលាតាមកម្រិតសាលានីមួយៗ

P → D→3




នៅក្នុង Folder 3 តំណាងអនុវិទ្យាល័យមាន 2 File៖

- File S.xlsm ៖ តំណាងសាលាអនុវិទ្យាល័យពី S1, S2,.,Sn
- File Total.xlsm ៖ សម្រាប់បូកសរុបពី S1, S2,…….,Sn

P → D→4




នៅក្នុង Folder 4 តំណាងវិទ្យាល័យមាន 2 File៖

- File H.xlsm ៖ តំណាងសាលាវិទ្យាល័យពី H1, H2, ….,Hn
- File Total.xlsm ៖ សម្រាប់បូកសរុបពី H1, H2, ….,Hn

# អំពីប្រព័ន្ធគ្រោងថវិកាគ្រឹះស្ថានសិក្សាសាធារណៈ(ត)



P → D→5




នៅក្នុង Folder 5 តំណាងអគារធនធានមាន 2 File៖

- File R.xlsm ៖ តំណាងអគារធនធានពី R1, R2,…….,Rn
- File Total.xlsm ៖ សម្រាប់បូកសរុបពី R1, R2,…….,Rn

P → D→6




នៅក្នុង Folder 6 តំណាងវិទ្យាល័យបច្ចេកទេសមាន 2 File៖

- File T.xlsm ៖ តំណាងសាលាវិទ្យាល័យបច្ចេកទេសពី T1, T2,…….,Tn
- File Total.xlsm ៖ សម្រាប់បូកសរុបពី T1, T2, …….,Tn

# ផ្នែកទី២៖

# ការបែងចែក File គ្រោងថវិកា

# ការបែងចែក File គ្រោងថវិកា



1

មន្ទីរអប់រំ យុវជន និងកីឡានឹងទទួលបាន File ពីក្រុមការងារប្រព័ន្ធ FMIS នៃនាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា រួចបង្កើត ជាបញ្ជីមួយដោយមានឈ្មោះលេខរៀង និង ឈ្មោះស្រុក។

| ខេត្ត.......................... | |
|---|---|
| ល.រ | ឈ្មោះស្រុក |
| 1 | |
| 2 | |
| 3 | |
| 4 | |
| 5 | |

2

Copy Folder D អោយទៅគ្រប់ការិយាល័យអប់រំស្រុកដែលមាននៅក្នុងបញ្ជី (អាច Copy ដោយ USB Flash ឬ ផ្ញើរតាមរយៈ Telegram, Email, ….)

* ចំណាំ៖ ការដាក់លេខរៀងអោយស្រុកគឺមានសារៈសំខាន់ដោយសារតែពេលបូកសរុប តម្រូវអោយដាក់ឈ្មោះស្រុកជាលេខ (D1, D2, D3, ………, Dn)

# ការបែងចែក File គ្រោងថវិកា ( ត )



3

បន្ទាប់ពីបាន File សម្រាប់គ្រោងថវិកាពីមន្ទីររួចហើយ ការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតបញ្ជីសាលា តាមអនុវិស័យ ដោយមានលេខរៀង និង ឈ្មោះសាលា ហើយត្រូវបែងចែក File ទាំងនោះបន្តអោយទៅសាលា។

ស្រុក....................................

| ល.រ | ឈ្មោះសាលាមត្តេយ្យ |
|---|---|
| 1 | |
| 2 | |
| 3 | |
| 4 | |
| 5 | |
| 6 | |
| 7 | |

ស្រុក....................................

| ល.រ | ឈ្មោះសាលាបឋមសិក្សា |
|---|---|
| 1 | |
| 2 | |
| 3 | |
| 4 | |
| 5 | |
| 6 | |
| 7 | |

ការ Copy ត្រូវបែងចែកដូចខាងក្រោម៖

- Folder 1→E.xlsm : ប្រគល់ជូនមត្តេយ្យសិក្សា
- Folder 2→P.xlsm : ប្រគល់ជូនបឋមសិក្សា
- Folder 3→S.xlsm : ប្រគល់ជូនអនុវិទ្យាល័យ
- Folder 4→H.xlsm : ប្រគល់ជូនវិទ្យាល័យ
- Folder 5→R.xlsm : ប្រគល់ជូនអគារធនធាន
- Folder 6→T.xlsm : ប្រគល់ជូនវិទ្យា.បច្ចេកទេស

# ការបែងចែក File គ្រោងថវិកា ( គ )



ក្រោយពីទទួលបាន File គ្រោងថវិកា សាលាគួរអនុវត្តដូចខាងក្រោម៖




1. ត្រូវ Copy File (ឬទាញយក File ពីទំនាក់ទំនងសង្គម) ដែលទទួលបានពីការិយាល័យអប់រំទុកកន្លែងដែលមានសុវត្ថិភាព ដោយមិនគួរដាក់ លើ Desktop ឬ Drive C ឡើយ
2. ចូលទៅកាន់ទីកន្លែង File ដែល ទទួលបានពីការិយាល័យអប់រំ រួចចុច Mouse ខាងស្តាំ (Right Click) → Copy

# ការបែងចែក File គ្រោងថវិកា ( ត )



បង្កើត Folder ថ្មី ដោយជ្រើសរើសទីតាំងសុវត្ថិភាព (ជ្រើសរើស Drive D) រួច Right Click លើចន្លោះទំនេរ → New → Folder ហើយដាក់ឈ្មោះអោយ Folder នោះ



# ការបែងចែក File គ្រោងថវិកា ( ត )



1. បន្ទាប់ពីបង្កើត Folder រួច ចូរចូលទៅក្នុង Folder ថ្មីនោះ ដោយចុច Mouse ពីរដង អោយញាប់ (Double Click) ឬ Right Click → Open ពេលនោះ ផ្ទាំង Windows ថ្មី នឹងបង្ហាញឡើង
2. Right Click លើចន្លោះទំនេរ រួចជ្រើសរើសយក Paste

ឧទាហរណ៍: សម្រាប់សាលាមត្តេយ្យដាច់






# ផ្នែកទី ៣៖

# ការគ្រោងថវិកាដំណើរការសាលា

# របស់គ្រឹះស្ថានសាធារណៈ

## ការបំពេញស្ថិតិសិស្ស និងគម្រោងថវិកា

នៅក្នុង File សម្រាប់គ្រោងថវិកាទាំងអស់ មាន Sheet មួយឈ្មោះថា ស្ថិតិសិស្ស និង គម្រោងថវិកា សម្រាប់សាលានីមួយៗបំពេញចំនួនសិស្ស និងគម្រោងថវិកាក្នុងគោលបំណងតាមដានថវិកាឆ្នាំកន្លងមក។

- សម្រាប់សាលាដាច់ត្រូវបំពេញចំនួនសិស្សតាមអនុវិស័យដែលសាលានោះស្ថិតនៅ និង គម្រោងថវិកាផងដែរ
- សម្រាប់សាលាបឋមសិក្សដែលមានសាលាមត្តេយ្យក្នុងនោះ ត្រូវបំពេញក្នុងជួរឈរចំនួនសិស្សមត្តេយ្យសិក្សា និងចំនួនសិស្សបឋមសិក្សា ព្រមទាំងថវិកាសរុបរួម (ញែកតែចំនួនសិស្ស) ហើយបញ្ចូលក្នុង File សម្រាប់គ្រោងបឋមសិក្សាតែប៉ុណ្ណោះ។
- សម្រាប់វិទ្យាល័យដែលមានអនុវិទ្យាល័យក្នុងនោះ ត្រូវបំពេញក្នុងជួរឈរចំនួនសិស្សអនុវិទ្យាល័យ និងចំនួនសិស្សវិទ្យាល័យ ព្រមទាំងថវិកាសរុបរួម (ញែកតែចំនួនសិស្ស) ហើយបញ្ចូលក្នុង File សម្រាប់គ្រោងវិទ្យាល័យតែប៉ុណ្ណោះ។

## 3 ការគ្រោងថវិកា SOB របស់គ្រឹះស្ថានសាធារណៈ



## ឧទាហរណ៍៖ សាលាបឋមសិក្សាជាក់មួយ

| សូមបំពេញឆ្នាំគ្រោងថវិកា ចំនួនសិស្សតាមអនុវិស័យ (បើមាន) និងគម្រោងថវិកាប្រចាំឆ្នាំ ក្នុងតារាងខាងក្រោម | | | | | | | |
|---|---|---|---|---|---|---|---|
| | ចំនួនសិស្ស | | | | | | |
| ឆ្នាំគ្រោងថវិកា | មត្តេយ្យសិក្សា | បឋមសិក្សា | អនុវិទ្យាល័យ | វិទ្យាល័យ | ចំនួនសិស្សវិទ្យាល័យបច្ចេកទេស | ចំនួនសិស្សសរុប | គម្រោងថវិកាសរុបប្រចាំឆ្នាំ (រៀល) |
| 2014 | | 310 | | | | 310 | 5,200,000 |
| 2015 | | 340 | | | | 340 | 5,800,000 |
| 2016 | | 350 | | | | 350 | 6,200,000 |
| 2017 | | 390 | | | | 390 | 7,100,000 |
| 2018 | | 417 | | | | 417 | 7,500,000 |
| 2019 | | | | | | - | |

Horizontal (Category) Axis Major Gridlines

ក្នុងឧទាហរណ៍គឺសម្រាប់សាលាបឋមសិក្សាជាក់មួយ។ បន្ទាប់ពីបញ្ចូលទិន្នន័យសិស្ស និងគម្រោងថវិកាតាមឆ្នាំកន្លងមក យើងអាចពិនិត្យមើលក្រាហ្វដែលនៅខាងក្រោមតារាងនេះបាន។ ការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យមើលទិន្នន័យនេះជាចាំបាច់ ដោយពិនិត្យមើលកំណើនសិស្ស និងថវិកា ពីមួយឆ្នាំទៅមួយឆ្នាំ។ នៅក្នុង Slide បន្ទាប់បង្ហាញពីក្រាហ្វបន្ទាប់ពីបញ្ចូលទិន្នន័យទាំងនេះ។

# ការគ្រោងថវិកា SOB របស់គ្រឹះស្ថានសាធារណៈ



## ឧទាហរណ៍៖ ក្រាហ្វបង្ហាញពីស្ថិតិសិស្ស



## ឧទាហរណ៍៖ ក្រាហ្វបង្ហាញពីស្ថិតិគម្រោងថវិកា



## ១. សាលាមត្តេយ្យសិក្សា

1. Right Click លើ File ឈ្មោះ E.xlsm → Open
2. ចូលទៅកាន់សន្លឹកកិច្ចការ (Sheet) ឈ្មោះ កុមារតូច នៅផ្នែកខាងក្រោម និងខាងឆ្វេង នៃ ផ្ទាំង Excel។ Sheet កុមារតូច គឺសម្រាប់ បំពេញព័ត៌មាន សាលាមត្តេយសិក្សា និង កំណត់ កញ្ចប់ថវិកា របស់សាលាមត្តេយ្យសិក្សាមួយ (ផ្អែកលើប្រកាស ៥០៨)។






# ៩. សាលាមត្តេយ្យសិក្សា

## ការកំណត់កញ្ចប់ថវិកា

1. បំពេញឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ
2. បំពេញឈ្មោះសាលា
3. ជ្រើសរើសតំបន់របស់សាលា (តំបន់ធម្មតា តំបន់ដាច់ស្រយាលនិង/ឬជួបការលំបាក)
4. ជ្រើសរើសចំនួនថ្នាក់ (សាលាមត្តេយ្យរដ្ឋមាន៣ថ្នាក់ចុះ/៤ថ្នាក់ឡើង)
5. បំពេញចំនួនសិស្ស រួចចុចរក្សាទុក

** សម្រាប់គម្រោងថវិកាឆ្នាំ ២០១៨ ក្រសួង សហវ បានផ្តល់ថវិកាបន្ថែម ចំនួន ២,៥០០,០០០/សា/ឆ្នាំ លើប្រកាស ៥០៨*



**កញ្ចប់ថវិកាដំណើរការសាលាមត្តេយ្យសិក្សា**

ប្រកាសអន្តរក្រសួង លេខ ៥០៨ សហវ ប្រក ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធី នៅ អ.យ.ក

ឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ: [1]

ការពង្រីកការអប់រំកុមារតូច

ឈ្មោះសាលា: [2]

កញ្ចប់ថវិកាសរុប: 0៛

| តំបន់ | ជ្រើសរើសចំនួនថ្នាក់ | ចំណាយ | ចំនួនសិស្ស | ឧបត្ថម្ភតាមច្បាប់ | ថវិកាបន្ថែម | សរុប |
|---|---|---|---|---|---|---|
| 3 | 4 | ចំណាយថេរ | | | 2,500,000៛ សាលា/ឆ្នាំ | 0៛ |
| | | ចំណាយអថេរ | 5 | | | 0៛ |

## ២. សាលាបឋមសិក្សា

1. Right Click លើ File ឈ្មោះ P.xlsm → Open
2. ចូលទៅកាន់សន្លឹកកិច្ចការ (Sheet) ឈ្មោះ បឋម នៅផ្នែកខាងក្រោម និងខាងឆ្វេង នៃផ្ទាំង Excel។ Sheet បឋម គឺសម្រាប់ បំពេញព័ត៌មាន សាលាបឋមសិក្សា និងកំណត់ កញ្ចប់ថវិកា របស់សាលាបឋមសិក្សាមួយ (ផ្អែកលើប្រកាស ៥០៨) ។






## ២. សាលាបឋមសិក្សា — *ការកំណត់កញ្ចប់ថវិកា (សាលាដាច់)*

1. បំពេញឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ
2. បំពេញឈ្មោះសាលា
3. ជ្រើសរើសប្រភេទសាលា (សាលាបឋមសិក្សា)
4. ជ្រើសរើសតំបន់របស់សាលា (តំបន់ធម្មតា តំបន់ដាច់ស្រយាលនិង/ឬជួបការលំបាក)
5. ជ្រើសរើសចំនួនថ្នាក់ (សាលាបឋមសិក្សាមាន ៦ថ្នាក់ចុះ/៧ថ្នាក់ឡើង)
6. បំពេញចំនួនសិស្ស រួចចុចរក្សាទុក

** សម្រាប់គម្រោងថវិកាឆ្នាំ ២០១៨ ក្រសួង សហវ បានផ្ដល់ថវិកាបន្ថែម ចំនួន ២,៥០០,០០០/សា/ឆ្នាំ លើប្រកាស ៥០៨*



## ២. សាលាបឋមសិក្សា — *ការកំណត់កញ្ចប់ថវិកា (សាលាមិនដាច់)*

1. បំពេញឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ
2. បំពេញឈ្មោះសាលា
3. ជ្រើសរើសប្រភេទសាលា (សាលាបឋមសិក្សា)
4. ជ្រើសរើសតំបន់របស់សាលា (តំបន់ធម្មតា តំបន់ដាច់ស្រយាលនិង/ឬជួបការលំបាក)
5. ជ្រើសរើសចំនួនថ្នាក់ (សាលាបឋមសិក្សាមាន ៦ថ្នាក់ចុះ/៧ថ្នាក់ឡើង)
6. បំពេញចំនួនសិស្សបឋមសិក្សា រួចចុចរក្សាទុក

** សម្រាប់គម្រោងថវិកាឆ្នាំ ២០១៨ ក្រសួង សហវ បានផ្តល់ថវិកាបន្ថែម ចំនួន ២,៥០០,០០០/សា/ឆ្នាំ លើប្រកាស ៥០៨*



**កញ្ចប់ថវិកាដំណើរការសាលាបឋមសិក្សា**

ប្រកាសអន្តរក្រសួង លេខ ៥០៨ សហវ ប្រក ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធី នៅ អ.យ.ក

| | |
|---|---|
| ឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ | 1 |
| ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសក្សា | |
| ឈ្មោះសាលា | 2 |
| ជ្រើសរើសប្រភេទសាលា | 3 |
| កញ្ចប់ថវិកាសរុប | 0៛ |

| តំបន់ | ជ្រើសរើសចំនួនថ្នាក់ | ចំណាយ | ចំនួនសិស្ស | ឧបត្ថម្ភតាមច្បាប់ | ថវិកាបន្ថែម | សរុប |
|---|---|---|---|---|---|---|
| 4 | 5 | ចំណាយថេរ | | | 2,500,000៛ សាលា/ឆ្នាំ | 0៛ |
| | | ចំណាយអថេរ | 6 | | | 0៛ |

## ២. សាលាបឋមសិក្សា *ការកំណត់កញ្ចប់ថវិកា (សាលាមិនដាច់)*

ចុច File → Save As ជ្រើសរើសទីតាំងផ្ទុករួច Save

1. ជ្រើសរើសប្រភេទសាលាទៅជា សាលាមត្តេយ្យសិក្សានៅក្នុងសាលាបឋមសិក្សា
2. បំពេញចំនួនសិស្សមត្តេយ្យសិក្សា រួចចុចរក្សាទុក

**កញ្ចប់ថវិកាដំណើរការសាលាបឋមសិក្សា**

ប្រកាសអន្តរក្រសួង លេខ ៥០៨ សហវ ប្រក ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធី នៅ អ.យ.ក

| | | | | | | |
|---|---|---|---|---|---|---|
| ឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ | | | | | | |
| ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា | | | | | | |
| ឈ្មោះសាលា | | | | | | |
| ជ្រើសរើសប្រភេទសាលា | 1 | | | | | |
| | | | | | កញ្ចប់ថវិកាសរុប | 0 |
| តំបន់ | ជ្រើសរើសចំនួនថ្នាក់ | ចំណាយ | ចំនួនសិស្ស | ឧបត្ថម្ភតាមច្បាប់ | ថវិកាបន្ថែម | សរុប |
| | | ចំណាយថេរ | | | 2,500,000៛ សាលា/ឆ្នាំ | 0 |
| | | ចំណាយអថេរ | 2 | | | 0 |

## ៣. សាលាអនុវិទ្យាល័យ

1. Right Click លើ File ឈ្មោះ S.xlsm → Open
2. ចូលទៅកាន់សន្លឹកិច្ចការ (Sheet) ឈ្មោះ អនុវិទ្យាល័យ នៅផ្នែកខាងក្រោម និងខាងឆ្វេង នៃ ផ្ទាំង Excel។ Sheet អនុវិទ្យាល័យ គឺសម្រាប់ បំពេញព័ត៌មាន សាលាអនុវិទ្យាល័យ និង កំណត់ កញ្ចប់ថវិកា របស់សាលាអនុវិទ្យាល័យមួយ (ផ្អែកលើប្រកាស ៥០៨) ។






## ៣. សាលាអនុវិទ្យាល័យ — *ការកំណត់កញ្ចប់ថវិកា (អនុ.ដាច់)*

1. បំពេញឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ
2. បំពេញឈ្មោះសាលា
3. ជ្រើសរើសប្រភេទសាលា (អនុវិទ្យាល័យ)
4. ជ្រើសរើសតំបន់របស់សាលា (តំបន់ធម្មតា តំបន់ដាច់ស្រយាលនិង/ឬជួបការលំបាក)
5. ជ្រើសរើសចំនួនថ្នាក់ (អនុវិទ្យាល័យរដ្ឋមាន១០ថ្នាក់ចុះ/១១ថ្នាក់ឡើង)
6. បំពេញចំនួនសិស្ស រួចចុចរក្សាទុក

** សម្រាប់គម្រោងថវិកាឆ្នាំ ២០១៨ ក្រសួង សហវ បានផ្តល់ថវិកាបន្ថែម ចំនួន ២,៥០០,០០០/សា/ឆ្នាំ លើប្រកាស ៥០៨*


ប្រកាសអន្តរក្រសួង លេខ ៥០៨ សហវ ប្រក ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធី នៅ អ.យ.ក

ឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ — 1

ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា

ឈ្មោះសាលា៖ — 2

ជ្រើសរើសប្រភេទសាលា — 3

កញ្ចប់ថវិកាសរុប 0៛

| តំបន់ | ជ្រើសរើសចំនួនថ្នាក់ | ចំណាយ | ចំនួនសិស្ស | ឧបត្ថម្ភតាមច្បាប់ | ថវិកាបន្ថែម | សរុប |
|---|---|---|---|---|---|---|
| 4 | 5 | ចំណាយថេរ | | | 2,500,000៛ សាលា/ឆ្នាំ | 0៛ |
| | | ចំណាយអថេរ | 6 | | | 0៛ |

## ៣. សាលាអនុវិទ្យាល័យ — *ការកំណត់កញ្ចប់ថវិកា (អនុ.មិនដាច់)*

1. បំពេញឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ
2. បំពេញឈ្មោះសាលា
3. ជ្រើសរើសប្រភេទសាលា (អនុវិទ្យាល័យ)
4. ជ្រើសរើសតំបន់របស់សាលា (តំបន់ធម្មតា តំបន់ដាច់ស្រយាលនិង/ឬជួបការលំបាក)
5. ជ្រើសរើសចំនួនថ្នាក់ (អនុវិទ្យាល័យរដ្ឋមាន១០ថ្នាក់ចុះ/១១ថ្នាក់ឡើង)
6. បំពេញចំនួនសិស្សអនុវិទ្យាល័យ រួចចុចរក្សាទុក

** សម្រាប់គម្រោងថវិកាឆ្នាំ ២០១៨ ក្រសួង សហវ បានផ្តល់ថវិកាបន្ថែម ចំនួន ២,៥០០,០០០/សា/ឆ្នាំ លើប្រកាស ៥០៨*

**កញ្ចប់ថវិកាដំណើរការសាលាថវិកាដំណើរការអនុវិទ្យាល័យ**

ប្រកាសអន្តរក្រសួង លេខ ៥០៨ សហវ ប្រក ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធី នៅ អ.យ.ក

| | |
|---|---|
| ឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ | (1) |
| ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា | |
| ឈ្មោះសាលា៖ | (2) |
| ជ្រើសរើសប្រភេទសាលា | អនុវិទ្យាល័យ (3) |

កញ្ចប់ថវិកាសរុប 0៛

| តំបន់ | ជ្រើសរើសចំនួនថ្នាក់ | ចំណាយ | ចំនួនសិស្ស | ឧបត្ថម្ភតាមច្បាប់ | ថវិកាបន្ថែម | សរុប |
|---|---|---|---|---|---|---|
| (4) | (5) | ចំណាយថេរ | | | 2,500,000៛ សាលា/ឆ្នាំ | 0៛ |
| | | ចំណាយអថេរ | (6) | | | 0៛ |

## ៣. សាលាអនុវិទ្យាល័យ

*ការកំណត់កញ្ចប់ថវិកា (សាលាមិនដាច់)*

ចុច File → Save As ជ្រើសរើសទីតាំងផ្ទុករួច Save

1. ជ្រើសរើសប្រភេទសាលាទៅជា បឋមសិក្សានៅក្នុងអនុវិទ្យាល័យ
2. បំពេញចំនួនសិស្សបឋមសិក្សា រួចចុចរក្សាទុក 



| | | | | | | |
|---|---|---|---|---|---|---|
| **កញ្ចប់ថវិកាដំណើរការសាលាថវិកាដំណើរការអនុវិទ្យាល័យ** | | | | | | |
| ប្រកាសអន្តរក្រសួង លេខ ៥០៨ សហវ ប្រក ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធី នៅ អ.យ.ក | | | | | | |
| ឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ | | | | | | |
| ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា | | | | | | |
| ឈ្មោះសាលា៖ | | | | | | |
| ជ្រើសរើសប្រភេទសាលា | បឋមសិក្សានៅក្នុងអនុវិទ្យាល័យ 1 | | | | | |
| | | | | | កញ្ចប់ថវិកាសរុប | 0៛ |
| **តំបន់** | **ជ្រើសរើសចំនួនថ្នាក់** | **ចំណាយ** | **ចំនួនសិស្ស** | **ឧបត្ថម្ភតាមច្បាប់** | **ថវិកាបន្ថែម** | **សរុប** |
| | | ចំណាយថេរ | | | 2,500,000៛ សាលា/ឆ្នាំ | 0៛ |
| | | ចំណាយអថេរ | 2 | | | 0៛ |

## ៤. សាលាវិទ្យាល័យ

1. Right Click លើ File ឈ្មោះ H.xlsm → Open
2. ចូលទៅកាន់សន្លឹកកិច្ចការ (Sheet) ឈ្មោះ វិទ្យាល័យ នៅផ្នែកខាងក្រោម និងខាងឆ្វេង នៃ ផ្ទាំង Excel។ Sheet វិទ្យាល័យ គឺសម្រាប់ បំពេញព័ត៌មាន សាលាវិទ្យាល័យ និង កំណត់ កញ្ចប់ថវិកា របស់សាលាវិទ្យាល័យមួយ (ផ្អែកលើប្រកាស ៥០៨) ។






## ៤. សាលាវិទ្យាល័យ — *ការកំណត់កញ្ចប់ថវិកា (សាលាដាច់)*

1. បំពេញឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ
2. បំពេញឈ្មោះសាលា
3. ជ្រើសរើសប្រភេទសាលា (វិទ្យាល័យ)
4. ជ្រើសរើសតំបន់របស់សាលា (តំបន់ធម្មតា តំបន់ដាច់ស្រយាលនិង/ឬជួបការលំបាក)
5. ជ្រើសរើសចំនួនថ្នាក់ (វិទ្យាល័យរដ្ឋមាន១០ថ្នាក់ចុះ/១១ថ្នាក់ឡើង)
6. បំពេញចំនួនសិស្ស រួចចុចរក្សាទុក

** សម្រាប់គម្រោងថវិកាឆ្នាំ ២០១៨ ក្រសួង សហវ បានផ្ដល់ថវិកាបន្ថែម ចំនួន ២,៥០០,០០០/សា/ឆ្នាំ លើប្រកាស ៥០៨*

**គណនាថវិកាដំណើរការសាលា**

ប្រកាសអន្តរក្រសួង លេខ ៥០៨ សហវ ប្រក ស្ដីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធី នៅ អ.យ.ក

| | |
|---|---|
| ឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ | 1 |
| ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា | |
| ឈ្មោះសាលា៖ | 2 |
| ជ្រើសរើសប្រភេទសាលា | វិទ្យាល័យ 3 |

| តំបន់ | ជ្រើសរើសចំនួនថ្នាក់ | ចំណាយ | ចំនួនសិស្ស | ឧបត្ថម្ភតាមច្បាប់ | ថវិកាបន្ថែម | សរុប |
|---|---|---|---|---|---|---|
| | | | | | កញ្ចប់ថវិកាសរុប | 0៛ |
| 4 | 5 | ចំណាយថេរ | | | 2,500,000៛ សាលា/ឆ្នាំ | 0៛ |
| | | ចំណាយអថេរ | 6 | | | 0៛ |

## ៤. សាលាវិទ្យាល័យ — *ការកំណត់កញ្ចប់ថវិកា (សាលាមិនដាច់)*

1. បំពេញឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ
2. បំពេញឈ្មោះសាលា
3. ជ្រើសរើសប្រភេទសាលា (វិទ្យាល័យ)
4. ជ្រើសរើសតំបន់របស់សាលា (តំបន់ធម្មតា តំបន់ដាច់ស្រយាលនិង/ឬជួបការលំបាក)
5. ជ្រើសរើសចំនួនថ្នាក់ (វិទ្យាល័យរដ្ឋមាន១០ថ្នាក់ចុះ/១១ថ្នាក់ឡើង)
6. បំពេញចំនួនសិស្សវិទ្យាល័យ រួចចុចរក្សាទុក

** សម្រាប់គម្រោងថវិកាឆ្នាំ ២០១៨ ក្រសួង សហវ បានផ្តល់ថវិកាបន្ថែម ចំនួន ២,៥០០,០០០/សា/ឆ្នាំ លើប្រកាស ៥០៨*



## ៤. សាលាវិទ្យាល័យ

*ការកំណត់កញ្ចប់ថវិកា (សាលាមិនដាច់)*

ចុច File → Save As ជ្រើសរើសទីតាំងផ្ទុករួច Save

1. ជ្រើសរើសប្រភេទសាលាទៅជា អនុវិទ្យាល័យនៅក្នុងវិទ្យាល័យ
2. បំពេញចំនួនសិស្សអនុវិទ្យាល័យ រួចចុចរក្សាទុក

**កញ្ចប់ថវិកាដំណើរការសាលា**

ប្រកាសអន្តរក្រសួង លេខ ៥០៨ សហវ ប្រក ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធី នៅ អ.យ.ក

| | | | | | | |
|---|---|---|---|---|---|---|
| ឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ | | | | | | |
| ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា | | | | | | |
| ឈ្មោះសាលា៖ | | | | | | |
| ជ្រើសរើសប្រភេទសាលា | អនុវិទ្យាល័យនៅក្នុងវិទ្យាល័យ (1) | | | | | |
| | | | | | កញ្ចប់ថវិកាសរុប | 0៛ |
| តំបន់ | ជ្រើសរើសចំនួនថ្នាក់ | ចំណាយ | ចំនួនសិស្ស | ឧបត្ថម្ភតាមច្បាប់ | ថវិកាបន្ថែម | សរុប |
| | | ចំណាយថេរ | | | 2,500,000៛ សាលា/ឆ្នាំ | 0៛ |
| | | ចំណាយអថេរ | (2) | | | 0៛ |

## ៥. អគារធនធាន

1. Right Click លើ File ឈ្មោះ R.xlsm → Open
2. ចូលទៅកាន់សន្លឹកកិច្ចការ (Sheet) ឈ្មោះ អគារធនធាន នៅផ្នែកខាងក្រោម និងខាងឆ្វេង នៃ ផ្ទាំង Excel។ Sheet អគារធនធាន គឺសម្រាប់ បំពេញព័ត៌មានអគារធនធាន និង កំណត់ កញ្ចប់ថវិកា របស់អគារធនធានមួយ (ផ្អែកលើប្រកាស ៥០៨) ។






## ៥. អគារធនធាន

### *ការកំណត់កញ្ចប់ថវិកា*

1. បំពេញឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ
2. បំពេញឈ្មោះសាលា
3. បំពេញលេខ 1 ក្នុងជួរឈរ ចំនួនអគារធនធាន។

**កញ្ចប់ថវិកាដំណើរការអគារធនធាន**

ប្រកាសអន្តរក្រសួង លេខ ៥០៨ សហវ ប្រក ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធី នៅ អ.យ.ក

| | | | | |
|---|---|---|---|---|
| ឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ | 1 | | | |
| ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា | | | | |
| ឈ្មោះសាលា៖ | 2 | | | |
| | | | កញ្ចប់ថវិកាសរុប | 0៛ |
| **អគារធនធាន** | **ចំនួនអគារ** | **ឧបត្ថម្ភតាមច្បាប់** | **ថវិកាបន្ថែម** | **សរុប** |
| ផ្តល់ថវិកាសម្រាប់ដំណើរការអគារធនធាន ៣៥លានរៀល ក្នុងមួយអគារ ក្នុងមួយឆ្នាំសិក្សា | 3 | 35,000,000៛ អគារ/ឆ្នាំ | | 0៛ |

## ៦. វិទ្យាល័យបច្ចេកទេស

1. Right Click លើ File ឈ្មោះ T.xlsm → Open
2. ចូលទៅកាន់សន្លឹកិច្ចការ (Sheet) ឈ្មោះ វិទ្យាល័យបច្ចេកទេស នៅផ្នែកខាងក្រោម និងខាងឆ្វេង នៃ ផ្ទាំង Excel។ Sheet វិទ្យាល័យបច្ចេកទេស គឺសម្រាប់ បំពេញ ព័ត៌មានវិទ្យាល័យបច្ចេកទេស និង កំណត់ កញ្ចប់ថវិកា របស់សាលា (ផ្អែកលើ ប្រកាស ៥០៨) ។






## ៦. វិទ្យាល័យបច្ចេកទេស

*ការកំណត់កញ្ចប់ថវិកា*

1. បំពេញឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ
2. បំពេញឈ្មោះសាលា
3. បំពេញលេខចំនួនសិស្ស ត្រង់ជួរឈរ សិស្ស និង ជួរដេកចំណាយអថេរ

**<u>កញ្ចប់ថវិកាដំណើរការវិទ្យាល័យបច្ចេកទេស</u>**

ប្រកាសអន្តរក្រសួង លេខ ៥០៨ សហវ ប្រក ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធី នៅ អ.យ.ក

ឈ្មោះការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ 1

លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស

ឈ្មោះសាលា៖ 2

កញ្ចប់ថវិកាសរុប 0៛

| | ចំណាយ | សិស្ស | ឧបត្ថម្ភតាមច្បាប់ | ថវិកាបន្ថែម | សរុប |
|---|---|---|---|---|---|
| | ចំណាយថេរ | | 50,000,000៛ សាលា/ឆ្នាំ | | 0៛ |
| | ចំណាយអ | 3 | 600,000៛ ម្នាក់/ឆ្នាំ | | 0៛ |

## ថវិកាដំណើរការសាលា (SOB)

បន្ទាប់ពីកំណត់កញ្ចប់ថវិការួច (គ្រប់សាលាទាំងអស់ត្រូវធ្វើដូចគ្នា) សូមបើ File រួចចូលទៅកាន់ Sheet ឈ្មោះ **គ្រោងថវិកា SOB** យើងនឹងឃើញកញ្ចប់ថវិកាសរុបបង្ហាញខ្លួនត្រង់ជួរដេក (Row) កញ្ចប់ថវិកា។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | កញ្ចប់ថវិកា | - | |
| លេខគណនី | | សម្ភារ ឬ សកម្មភាព | | | ចំណាយប្រចាំ | | ចំណាយមិនប្រចាំ | | សរុប |
| | | ឈ្មោះសម្ភារៈ | ឯកតា | តំលៃឯកតា(រៀល) | បរិមាណ | ចំណាយ | បរិមាណ | ចំណាយ | |
| | | | 1 | 2 | 3 | 4=2*3 | 5 | 6=2*5 | 7=4+6 |
| **សរុបរួម** | | | | | | - | | - | - |
| **សម្ភារមូលដ្ឋាន** | | | | | | - | | - | - |
| | 60021 | **សម្ភារការិយាល័យ** | | | | - | | - | - |
| | | ក្រដាសរ៉ាម | | | | - | | - | - |
| | | | | | | - | | - | - |
| | 60022 | **សៀវភៅមើល និងឯកសារផ្សេងៗ** | | | | - | | - | - |
| | | វចនានុក្រម | | | | - | | - | - |
| | | | | | | - | | - | - |
| | 60023 | **ការបោះពុម្ព** | | | | - | | - | - |
| | | បោះពុម្ពសៀវភៅ | | | | - | | - | - |
| | | | | | | - | | - | - |

## ការគ្រោងថវិកា SOB របស់គ្រឹះស្ថានសាធារណៈ (ត)



ដើម្បីងាយស្រួលក្នុងការពិនិត្យមើលលើមុខសញ្ញាចំណាយ និងអនុគណនីនោះ នៅក្រោមអនុគណនីនីមួយៗត្រូវបាន Hide (ជួរដេក) Row ជាច្រើន បង្កប់ជាមួយនូវមុខទំនិញ ឬសម្ភារៈផងដែរ ហើយមុខសញ្ញាចំណាយទាំងនោះមាន៖

- សម្ភារមូលដ្ឋាន
- ការកែលម្អបរិស្ថាន សាលា និងថ្នាក់រៀន
- ការជួសជុលតូច (សង្ហារឹម បណ្ណាល័យ និងបរិក្ខារអេឡិចត្រូនិច)
- ការទិញសៀវភៅអានដាក់ក្នុងបណ្ណាល័យ
- បំណិនជីវិត (កីឡា សិល្បៈ រោងជាង គេហវិជ្ជា និងកសិកម្ម)
- ចំណាយសម្រាប់អនាម័យ
- ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក
- ការរៀបចំឯកសារធ្វើតេស្ត និងសម្ភារផ្សេងៗសម្រាប់ប្រឡងឆមាស
- ចលនាបីល្អ (សិស្សល្អ មិត្តល្អ កូនល្អ) របស់ក្រុមប្រឹក្សាយុវជន
- ចំណាយផ្សេងៗ

## ថវិកាដំណើរការសាលា (SOB)

ដើម្បីអាចគ្រោងតាមមុខសញ្ញាចំណាយ ចូរជ្រើសរើសអនុគណនីដែលមានស្រាប់នៅក្រោមមុខចំណាយនីមួយៗ។ បង្ហាញ Row ដែលបាន Hide ដោយធ្វើការ Select Row ក្រោមអនុគណនីដែលចង់បង្ហាញ រហូតដល់ Row បន្ទាប់ (2 Rows) បន្ទាប់មក Right Click លើ Row Header → Unhide



## ថវិកាដំណើរការសាលា (SOB)

ចំពោះសម្ភារៈ ឬទំនិញទាំងនេះអាច លុប កែប្រែ ឬថែមថ្មីបាន

អំពីចំណាយ៖

- ចំណាយប្រចាំ៖ ជាចំណាយដែលត្រូវការជារៀងរាល់ឆ្នាំ (ទិញក្រដាសរ៉ាម, ទឹកថ្នាំ Printer...)
- ចំណាយមិនប្រចាំ៖ ជាចំណាយដែលប្រើតែម្តងចប់ (លាបថ្នាំរបង, ទិញម៉ាស៊ីនថតចម្លង........)

| | អនុគណនី | សម្ភារ ឬ សកម្មភាព | | | ចំណាយប្រចាំ | | ចំណាយមិនប្រចាំ | | សរុប |
|---|---|---|---|---|---|---|---|---|---|
| | | ឈ្មោះសម្ភារៈ | ឯកតា | តំលៃឯកតា(រៀល) | បរិមាណ | ចំណាយ | បរិមាណ | ចំណាយ | |
| | | | 1 | 2 | 3 | 4=2*3 | 5 | 6=2*5 | 7=4+6 |
| **សរុបរួម** | | | | | | - | | - | - |
| **សម្ភារមូលដ្ឋាន** | | | | | | - | | - | - |
| | 60021 | **សម្ភារការិយាល័យ** | | | | - | | - | - |
| | | ក្រដាសរ៉ាម | កេះស | | | - | | - | - |
| | | ខ្មៅដៃ | | | | - | | - | - |
| | | បណ្តូលខ្មៅដៃចុច | | | | - | | - | - |
| | | ក្រដាសរ៉ាម | | | | - | | - | - |
| | | ស៊ីមីទន់ | | | | - | | - | - |
| | | ស៊ីមីរឹង | | | | - | | - | - |
| | | ស៊ីមីចងខ្សែ | | | | - | | - | - |

## ថវិកាដំណើរការសាលា (SOB)

ពេលគ្រោង បើមានពណ៌ក្រហមត្រង់ Cell ណាមួយ បញ្ជាក់ថាការគ្រោងមានបញ្ហា។ Cell ក្រហមក្នុងរូបខាងក្រោមគឺបណ្ដាលមកពីគ្រោងលើសកញ្ចប់ថវិកា។

**មូលដ្ឋានគិតគម្រោងចំណាយថវិកាសម្រាប់ឆ្នាំ ២០.........**

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| កញ្ចប់ថវិកា | | | | | | | | | 3,800,000 |
| អនុគណនី | | សម្ភារ ឬ សកម្មភាព | | | ចំណាយប្រចាំ | | ចំណាយមិនប្រចាំ | | សរុប |
| | | ឈ្មោះសម្ភារៈ | ឯកតា | តំលៃឯកតា(រៀល) | បរិមាណ | ចំណាយ | បរិមាណ | ចំណាយ | |
| | | | 1 | 2 | 3 | 4=2*3 | 5 | 6=2*5 | 7=4+6 |
| **សរុបរួម** | | | | | | 4,000,000 | | - | 4,000,000 |
| សម្ភារមូលដ្ឋាន | | | | | | 4,000,000 | | - | 4,000,000 |
| | 60021 | សម្ភារការិយាល័យ | | | | 4,000,000 | | - | 4,000,000 |
| | | ក្រដាសរ៉ាម | កេះស | 80,000 | 25 | 2,000,000 | | - | 2,000,000 |
| | | ខ្មៅដៃ | | | | - | | - | - |
| | | បណ្ដូលខ្មៅដៃចុច | | | | - | | - | - |
| | | | | | | - | | - | - |
| | | សីមីទន់ | ដុំ | 40,000 | 50 | 2,000,000 | | - | 2,000,000 |
| | | សីមីរឹង | | | | - | | - | - |
| | | សីមីចងខ្សែ | | | | - | | - | - |
| | | កន្ត្រៃ | | | | - | | - | - |

## ថវិកាដំណើរការសាលា (SOB)

បន្ទាប់ពីគ្រោងតាមតាមមុខចំណាយរួចហើយ សាលាត្រូវធ្វើការបែងចែកថវិកាតាមត្រីមាស។

- ចូលទៅកាន់ Sheet TotalByExp ដើម្បីបែងចែកថវិកាតាមត្រីមាស។
- ជាការកំណត់ស្រាប់ ថវិការបស់អនុគណនីនីមួយៗត្រូវបានចែកជា ៤ ស្មើៗគ្នា ដោយទឹ្សេក សំណល់ដែលចែកមិនដាច់ ត្រូវបានបូកបញ្ចូលក្នុងត្រីមាសទី១ ហើយអាចកែប្រែបាន។ ប្រសិនបើ យើងចែកតាមត្រីមាស ហើយសរុបទាំង ៤ ត្រីមាសមិនស្មើគ្នា (A មិនស្មើ B) នោះនឹងមានពណ៌ ក្រហម បង្ហាញឡើងដែលបញ្ជាក់ថាមានកំហុសក្នុងការបែងចែក។ ចូរបែងចែកធ្វើយ៉ាងណាអោយ ផលបូកសរុបទាំង ៤ ត្រីមាស (B) ស្មើនឹងចំណុច (A)។

| អនុគណនី | ចំណាយប្រចាំ | ចំណាយមិនប្រចាំ | សរុប | ចំណែងចែកតាមត្រីមាស | | | | |
|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | សរុប |
| | | - | 6,000,000 | 1,500,000 | 1,500,000 | 1,500,000 | 1,500,000 | 6,000,000 |
| | | - | 6,000,000 | 1,500,000 | 1,500,000 | 1,500,000 | 1,500,000 | 6,000,000 |
| | | - | 6,000,000 | 1,500,000 | 1,500,000 | 1,500,000 | 1,500,000 | 6,000,000 |
| | | - | 4,000,000 | 1,000,000 | 1,000,000 | 1,000,000 | 1,000,000 | 4,000,000 |
| | | - | - | - | - | - | - | - |
| | | - | - | - | - | - | - | - |
| | | - | 2,000,000 | 500,000 | 500,000 | 500,000 | 500,000 | 2,000,000 |
| | | - | - | - | - | - | - | - |
| | | - | - | - | - | - | - | - |

A B

| ចំណាយប្រចាំ | ចំណាយមិនប្រចាំ | សរុប | ចំណែងចែកតាមត្រីមាស | | | | |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | សរុប |
| 6,000,000 | - | 6,000,000 | 1,000,000 | 1,500,000 | 1,500,000 | 1,500,000 | 5,500,000 |
| 6,000,000 | - | 6,000,000 | 1,000,000 | 1,500,000 | 1,500,000 | 1,500,000 | 5,500,000 |
| 6,000,000 | - | 6,000,000 | 1,000,000 | 1,500,000 | 1,500,000 | 1,500,000 | 5,500,000 |
| 4,000,000 | - | 4,000,000 | 1,000,000 | 1,000,000 | 1,000,000 | 1,000,000 | 4,000,000 |
| - | - | - | - | - | - | - | - |
| - | - | - | - | - | - | - | - |
| 2,000,000 | - | 2,000,000 | | 500,000 | 500,000 | 500,000 | 1,500,000 |

## ថវិកាដំណើរការសាលា (SOB)

- បន្ទាប់ពី ធ្វើការគ្រោង ក្នុង Sheet គ្រោងថវិកា SOB, TotalByExp រួច ចូលទៅ Sheet TotalSOBBySubaccount នោះយើងនឹងឃើញថវិកាដែលបានគ្រោងនឹងបង្ហាញតាមចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកា។
- Sheet ទាំង ៣ នេះត្រូវតែមានតណទានថវិកាដំណើរការសាលារុបរួមស្មើគ្នា



# ផ្នែកទី៤៖

# ការគ្រោងថវិកាអាហារូបករណ៍

# និងបង្គន់ ទឹកស្អាត និងអនាម័យ

## អាហារូបករណ៍

ជាទូទៅ អាហារូបករណ៍មានចាប់ពីកម្រិតបឋមសិក្សាឡើងទៅ។ ដើម្បីគ្រោងថវិកាអាហារូបករណ៍ ត្រូវចូលទៅកាន់ Sheet គ្រោងអាហារូបករណ៍ ដែលនៅក្នុងនោះយើងអាចគ្រោងបានតាមសាលា និងមានលក្ខណៈខុសគ្នាទៅតាមអនុវិស័យនីមួយៗ ហើយថវិកាអាហារូបករណ៍នឹងត្រូវបានបូកសរុបក្នុងអនុគណនី 62025 ដោយស្វ័យប្រវត្តិ។

- ករណីសាលាបឋមសិក្សា ដល់មធ្យសិក្សា ការគ្រោងអាហារូបរកណ៍ត្រូវបានយកនិយាមតាមអនុក្រឹត្យ ៣៨ អនក្រ.បក ស្តីពីការផ្តល់អាហារូបករណ៍ដល់សិក្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ។
- វិទ្យាល័យបច្ចេកទេស ការគ្រោងអាហារូបករណ៍ត្រូវបានយកនិយាមតាមអនុក្រឹត្យ ១៧៤ អនក្រ.បក ស្តីពីអាហារូបករណ៍ និងរបបឧបត្ថម្ភជីវភាពអន្តេវាសិក សម្រាប់សិស្ស និងនិស្សិតតាមគ្រឹះស្ថានសិក្សាសាធារណៈ។

## អាហារូបករណ៍ *ថ្នាក់បឋមសិក្សា*

1. ជ្រើសរើសប្រភេទចំណាយ (ចំណាយប្រចាំ/ចំណាយមិនប្រចាំ)
2. បញ្ចូលចំនួនសិស្សអាហារូបករណ៍

| គ្រោងចំណាយលើអាហារូបករណ៍ | | | | | |
|---|---|---|---|---|---|
| ប្រភេទចំណាយ | ចំណាយប្រចាំ (1) | | | | |
| ប្រភេទសិស្ស | ចំនួនសិស្ស អាហារូបករណ៍សរុប | ចំនួនសិស្ស ត្រូវទទួលអាហារូបករណ៍ | រយៈពេលសិក្សា | ឧបត្ថម្ភ (៛) | សរុប |
| **សរុប** (62025) | | | | | - |
| សិស្សក្រីក្រ | | | | | - |
| បឋមសិក្សា | (2) | - | 1 ឆ្នាំ | 240,000 | - |

## អាហារូបករណ៍ មធ្យមសិក្សាបឋមភូមិ

1. ជ្រើសរើសប្រភេទចំណាយ (ចំណាយប្រចាំ/ចំណាយមិនប្រចាំ)
2. បញ្ចូលចំនួនសិស្សអាហារូបករណ៍

| គ្រោងចំណាយលើអាហារូបករណ៍ | | | | | |
|---|---|---|---|---|---|
| ប្រភេទចំណាយ | ចំណាយប្រចាំ (1) | | | | |
| ប្រភេទសិស្ស | ចំនួនសិស្ស អាហារូបករណ៍សរុប | ចំនួនសិស្ស ត្រូវទទួលអាហារូបករណ៍ | រយៈពេលសិក្សា | ឧបត្ថម្ភ (៛) | សរុប |
| **សរុប** ( 62025 ) | | | | | - |
| សិស្សក្រីក្រ | | | | | - |
| មធ្យមសិក្សាបឋមភូមិ | (2) | - | 1 ឆ្នាំ | 240,000 | - |

## អាហារូបករណ៍ | មធ្យមសិក្សាទុតិយភូមិ

1. ជ្រើសរើសប្រភេទចំណាយ (ចំណាយប្រចាំ/ចំណាយមិនប្រចាំ)
2. បញ្ចូលចំនួនសិស្សអាហារូបករណ៍

| គ្រោងចំណាយលើអាហារូបករណ៍ | | | | | |
|---|---|---|---|---|---|
| ប្រភេទចំណាយ | ចំណាយប្រចាំ (1) | | | | |
| ប្រភេទសិស្ស | ចំនួនសិស្ស អាហារូបករណ៍សរុប | ចំនួនសិស្ស ត្រូវទទួលអាហារូបករណ៍ | រយៈពេលសិក្សា | ឧបត្ថម្ភ (៛) | សរុប |
| **សរុប** (62025) | | | | | - |
| សិស្សក្រីក្រ | | | | | - |
| មធ្យមសិក្សាទុតិយភូមិ | (2) | - | 1 ឆ្នាំ | 360,000 | - |

## អាហារូបករណ៍ *សិស្ស-និស្សិត*

1. ជ្រើសរើសប្រភេទចំណាយ (ចំណាយប្រចាំ/ចំណាយមិនប្រចាំ)
2. បញ្ចូលចំនួនសិស្សអាហារូបករណ៍
3. បញ្ចូលរយៈពេលសិក្សា (គិតជាខែ)

អនុក្រឹត្យ ១៧៤ អនក្រ.បក សម្រាប់សិស្សកម្រិតមធ្យមសិក្សាឯកទេស ទទួលបាន ៣០% និង ៣៥% សម្រាប់សិក្សកម្រិតបឋមសិក្សាឯកទេសនៃចំនួនសិស្សអាហារូបករណ៍សរុប

| ផែនការចំណាយលើអាហារូបករណ៍ | | | | | |
|---|---|---|---|---|---|
| ប្រភេទចំណាយ | ចំណាយប្រចាំ (1) | | | | |
| ប្រភេទសិស្ស | ចំនួនសិស្ស អាហារូបករណ៍សរុប | ចំនួនសិស្ស ត្រូវទទួលអាហារូបករណ៍ | រយៈពេលសិក្សា | ឧបត្ថម្ភ (៛) | សរុប |
| **សរុប** (62025) | | | | | - |
| សិស្ស-និស្សិត | (2) | | (3) | | - |
| កម្រិតមធ្យមសិក្សាឯកទេស | | - | | 40,000 | - |
| កម្រិតបឋមសិក្សាឯកទេស | | - | | 30,000 | - |

## អាហារូបករណ៍ — ពិនិត្យមើលឥណទានដែលបានគ្រោង

- បន្ទាប់ពីបញ្ចូលគ្រោងអាហារូបករណ៍រួច យើងអាចមើលផ្នែកខាងក្រោម យើងនឹងឃើញតារាងមានទិន្នន័យដែលយើងបានគ្រោង និងអាចមើលក្នុង Sheet TotalByExp រួចទាញ Scroll ទៅផ្នែកខាងក្រោម យើងនឹងឃើញទិន្នន័យដែលបាគ្រោងផងដែរ។

| គ្រោងចំណាយលើអាហារូបករណ៍ | | | | |
|---|---|---|---|---|
| | ប្រភេទសិស្ស | សរុបប្រចាំ | សរុបមិនប្រចាំ | សរុប |
| សរុប អនុគណនី 62025 | | 16,800,000 | - | 16,800,000 |
| សិស្សក្រីក្រ | | 16,800,000 | - | 16,800,000 |
| | បឋមសិក្សា | 16,800,000 | - | 16,800,000 |
| | មធ្យមសិក្សាបឋមភូមិ | - | - | - |
| | មធ្យមសិក្សាទុតិយភូមិ | - | - | - |
| សិស្ស-និស្សិត | | - | - | - |
| | កម្រិតមធ្យមសិក្សាឯកទេស | - | - | - |
| | កម្រិតបឋមសិក្សាឯកទេស | - | - | - |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សរុបថវិកាអាហារូបករណ៍ | | | 16,800,000 | - | 16,800,000 | | | | | 16,800,000 |
| អាហារូបករណ៍ | | | 16,800,000 | - | 16,800,000 | | | | | 16,800,000 |
| | 62025 | អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្នុងប្រទេស | 16,800,000 | - | 16,800,000 | | | | | 16,800,000 |

## គ្រោងបង្គន់ ទឹកស្អាត និងអនាម័យ

ដើម្បីគ្រោងបង្គន់ ទឹកស្អាត និងអនាម័យ យើងត្រូវចូលទៅក្នុង Sheet គ្រោងបង្គន់

1. ជ្រើសរើសចំណាយ (ចំណាយប្រចាំ/ចំណាយមិនប្រចាំ)
2. បំពេញចំនួនបង្គន់ដែលទទួលបាន។
3. សម្រាប់ថ្លៃឯកតាអាចប្រែប្រួល (13,800,000រៀល) ក្នុងឆ្នាំ ២០១៨

ចំពោះការគ្រោងបង្គន់អនាម័យនឹងត្រូវបានបូករុបក្នុងអនុគណនី 61052

| តារាងគ្រោងបង្គន់-ទឹកស្អាត-អនាម័យ | | | |
|---|---|---|---|
| ប្រភេទចំណាយ | ចំណាយប្រចាំ (1) | | សរុប |
| **សរុប** | | | - |
| ចំនួនបង្គន់អនាម័យ | (2) | 13,800,000 (3) | - |

## គ្រោងបង្គន់ ទឹកស្អាត និងអនាម័យ

### *ពិនិត្យមើលឥណទានដែលបានគ្រោង*

បន្ទាប់ពីបញ្ចូលគ្រោងបង្គន់អនាម័យរួច យើងអាចមើលផ្នែកខាងក្រោម យើងនឹងឃើញតារាងមានទិន្នន័យដែលយើងបានគ្រោង និងអាចមើលក្នុង Sheet TotalByExp រួចទាញ Scroll ទៅផ្នែកខាងក្រោម យើងនឹងឃើញទិន្ន័យដែលបាគ្រោងផងដែរ។

| គ្រោងចំណាយលើបន្ទប់-ទឹកស្អាត-អនាម័យ | | | |
|---|---|---|---|
| | សរុបប្រចាំ | សរុបមិនប្រចាំ | សរុប |
| សរុប អនុគណនី 61052 | 13,800,000 | - | 13,800,000 |
| បង្គន់អនាម័យ | 13,800,000 | - | 13,800,000 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សរុបថវិកាបន្ទប់-ទឹកស្អាត-អនាម័យ | | | 13,800,000 | - | 13,800,000 | | | | | 13,800,000 |
| បង្គន់អនាម័យ | | | 13,800,000 | - | 13,800,000 | | | | | 13,800,000 |
| | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ | 13,800,000 | - | 13,800,000 | | | | | 13,800,000 |

ម្យ៉ាងទៀត សាលាអាចមើលគម្រោងថវិការបស់ខ្លួនសរុបបាននៅក្នុង Sheet ឈ្មោះ Total_SOB_SCL_Tiolet ដែលក្នុង Sheet នេះគឺសម្រាប់សរុបគម្រោងថវិកាទាំង ថវិកាដំណើរការសាលា SOB, ថវិកាអាហារូបករណ៍ និងថវិកាបង្គន់អនាម័យ។

**គម្រោងចំណាយថវិកាប្រចាំឆ្នាំ**

ឯកតា៖ រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ចំណាយប្រចាំ | ចំណាយមិនប្រចាំ | សរុប |
|---|---|---|---|---|---|---|
| | | | | 1 | 2 | 3=1+2 |
| សរុបរួមចំណាយថវិ[illegible] | | | | 4,000,000 | 500,000 | 4,500,000 |
| ក. សរុបចំណាយចរន្ត (ក្រុមទី ១+ក្រុមទី ២) | | | | 4,000,000 | 500,000 | 4,500,000 |
| ក្រុមទី ១ : ចំណាយពិត (ប្រភេទទី ១ + ប្រភេទទី ២ + ប្រភេទទី ៣ + ប្រភេទទី ៤) | | | | 4,000,000 | 500,000 | 4,500,000 |
| ប្រភេទទី ១ : មធ្យោបាយ និងសេវា | | | | 4,000,000 | 500,000 | 4,500,000 |

Total_SOB_SCL_Tiolet

កម្មវត្ថុ | គម្រោងថវិកា SOB | គម្រោងបង្គន់ | TotalByExp | Total_SOB_SCL_Tiolet | TotalSOBBySubAccount

# ផ្នែកទី ៥៖

# ការគ្រោងថវិកា

# របស់ការិយាល័យអប់រំ យុវជន និងកីឡា

# ក្រុង ស្រុក ខណ្ឌ

ការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ អាចធ្វើការគ្រោងថវិកាក្នុងជំពូក ៦០ និង ៦១ ព្រមទាំងការគ្រោងថវិកាចុះពិនិត្យតាមដានការងារបច្ចេកទេសតាមសាលារៀនក្នុងរង្វង់ដែនដី ក្រុង ស្រុក ខណ្ឌ ដែលមានកញ្ចប់រួមច្រើនបំផុតសរុប ២៤លានរៀល (ឬអាចតិចជាងនេះ)។ Copy File District_Plan.xlsm ដែលស្ថិតនៅក្នុង Folder D ទុកក្នុងទីតាំងមានសុវត្ថិភាព រួចបើក File នោះដើម្បីគ្រោងថវិការបស់ការិយាល័យ។



## គ្រោងដំណើរការិយាល័យ

ថវិកា ២៤លានរៀល (គិតទាំងថវិកាចុះពិនិត្យតាមដានការងារបច្ចេកទេសតាមសាលា) ត្រូវវិភាជន៍ក្នុងជំពូក ៦០ និង ៦១។ សូមចូលទៅក្នុង Sheet មុខចំណាយ ដើម្បីគ្រោងថវិកានេះ។

- បញ្ចូលឈ្មោះសម្ភារ, ឯកតា និងបរិមាណតម្រូវការតាមអនុគណនី
- នៅក្រោម Row អនុគណនី មាន Row ជាច្រើនត្រូវបានលាក់ (Hide) ដែលយើងអាចUnhide បាន។

**មូលដ្ឋានគិតគម្រោងចំណាយថវិកាសម្រាប់ឆ្នាំ ២០………**

| កញ្ចប់ថវិកា | | | | | | 24,000,000 | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ជំពូក | គណនី | អនុគណនី | ឈ្មោះសម្ភារៈ / ទំនិញ | ឯកតា | តម្លៃឯកតា | ចំណាយប្រចាំ | | ចំណាយមិនប្រចាំ | | សរុប |
| | | | | | | បរិមាណ | ចំណាយ | បរិមាណ | ចំណាយ | |
| **សរុប** | | | | | | | - | | - | - |
| 60 | | | **ការទិញ** | | | | - | | - | - |
| | 6001 | | **សម្ភារ ផ្គត់ផ្គង់ថែទាំ** | | | | - | | - | - |
| | | 60011 | សម្ភារផ្គត់ផ្គង់សម្អាត និងអនាម័យ | | | | - | | - | - |
| | | | | | | | - | | - | - |
| | | 60012 | សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ | | | | - | | - | - |
| | | | | | | | - | | - | - |
| | | 60013 | សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំផ្លូវថ្នល់ ស្ពាន និងលូ | | | | - | | - | - |

## គ្រោងចុះពិនិត្យការងារបច្ចេកទេស

ការគ្រោងចុះពិនិត្យតាមដានការងារបច្ចេកទេសនេះគឺយកនិយាមតាមលិខិត ៧៧៧៨ សហវ. អថ ដោយប្រើអនុគណនី 61128។ ចូលទៅក្នុង Sheet ពិនិត្យបច្ចេកទេសសាលា៖

1. ជ្រើសរើសចំណាយ (ចំណាយប្រចាំ/ចំណាយមិនប្រចាំ)
2. បំពេញចំនួនចុះពិនិត្យតាមដាន
3. បំពេញចំនួនថ្ងៃក្នុង ១លើក
4. បំពេញចំនួនមន្ត្រីក្នុង១លើក

| លិខិតលេខ ៧៧៧៨ សហវ អថ | | |
|---|---|---|
| សម្រាប់មន្ត្រីអប់រំចុះតាមដានការងារបច្ចេកទេសនៅតាមសាលារៀន ក្នុងរង្វង់ក្រុង ស្រុក ខណ្ឌ | | |
| ប្រភេទចំណាយ | ចំណាយប្រចាំ (1) | |
| **សរុប** (61128) | | - |
| ចំនួនលើក | (2) | |
| ចំនួនថ្ងៃ | (3) | |
| ចំនួនមន្ត្រី | (4) | |

# ផ្នែកទី ៦៖

# ការបូកសរុបគម្រោងថវិកា

# របស់គ្រឹះស្ថានសាធារណៈ

# ការបូកសរុបគម្រោងថវិការបស់គ្រឹះស្ថានសាធារណៈ



ការបូកសរុបគម្រោងថវិកាជាបន្ទុករបស់ការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ ដោយត្រូវបូកសរុបតាមអនុវិស័យ ព្រមទាំងបូកសរុបគម្រោងថវិការបស់ខ្លួនផងដែរ។

- ចូរបង្កើត Folder ថ្មីក្នុងទីតាំងដែលមានសុវត្ថិភាព (សូមអោយឈ្មោះថា D)
- ចូលក្នុង Folder D រួចបង្កើត Folder ទៅតាមចំនួនអនុវិស័យដែលមានក្នុងស្រុកនីមួយៗ។




- Copy File District_Plan.xlsm ដែលបានគ្រោងរួចដោយការិយាល័យអប់រំ ចូលក្នុង Folder D
- Copy File Total_Schools_and_District.xlsm ដែលទទួលបានពីមន្ទីរ ចូលក្នុង Folder D

**គ្រប់ File និង Folder ទាំងអស់ចាប់ពីទីតាំង Drive ត្រូវសរសេរជាភាសាអង់គ្លេស និងមិនគួរដាក់ក្នុងទីតាំងវែងពេក*

## អំពី File Total.xlsm

File Total.xlsm ជា File សម្រាប់សរុបគម្រោងថវិកាតាមអនុវិស័យ (ស្ថិតក្នុង Folder លេខ 1 ដល់ Folder លេខ 6)។ ក្នុង File នេះ មានបង្ហាញ Sheet ចំនួន 7៖

1. Master: សម្រាប់បំពេញព័ត៌មានរបស់អនុវិស័យ
2. TotalByExp: សម្រាប់បូកសរុបថវិកាតាមមុខសញ្ញាចំណាយ
3. Total_SOB_SCL_BySubaccount: សម្រាប់បូករុបថវិការួមទាំងអស់ (SOB, អាហារូបករណ៍ និង បង្គន់អនាម័យ) តាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា
4. Toilet: សម្រាប់បូកសរុបគម្រោងបង្គន់អនាម័យ
5. TotalSOBBySubAccount: សម្រាប់បូកសរុបគម្រោងថវិកាដំណើរការសាលា តាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិការថវិកា
6. TOTAL_SOB: សម្រាប់បូកសរុបគម្រោង SOB តាមមុខសញ្ញាចំណាយ
7. TOTAL_SCL: សម្រាប់បូកសរុបគម្រោងអាហារូបករណ៍



បូកសរុបគម្រោងថវិកា | ថ្នាក់ស្រុក | អប់រំកុមារតូច

Copy File ដែលសាលាមត្តេយ្យដាច់ រួមទាំងសាលាមត្តេយ្យដែលនៅជាមួយសាលាបឋមសិក្សា បានគ្រោងរួចចូលក្នុង Folder លេខ 1 ។ មុនពេល Copy មើលបញ្ជីថាតើសាលានោះនៅលេខរៀងទីប៉ុន្មាន រួចដូរឈ្មោះអោយស្របតាមលេខរៀងនោះដោយផ្តើមដោយអក្សរដែលបានកំណត់។

ស្រុក កណ្តាលស្ទឹង

| ល.រ | ឈ្មោះសាលាមត្តេយ្យ |
|---|---|
| 1 | សាលាមត្តេយ្យសិក្សាអន្លង់រមៀត |
| 2 | សាលាមត្តេយ្យសិក្សាគោកត្រប់ |
| 3 | |




ឧទាហរណ៍៖ សម្រាប់មត្តេយ្យសិក្សា

- ដូរឈ្មោះ File របស់សាលាមត្តេយ្យអន្លង់រមៀតទៅជា E1.xlsm ដោយ Right Click លើ File នោះ → Rename → វាយឈ្មោះថ្មី (E1.xlsm) រួច Copy ចូលក្នុង Folder 1 នៃទីតាំងបូកសរុប
- ដូរឈ្មោះ File របស់សាលាមត្តេយ្យសិក្សាគោកត្រប់ទៅជា E2.xlsm Copy ចូលក្នុង Folder 1 នៃទីតាំងបូកសរុប
- Copy File ឈ្មោះ Total.xlsm ដែលទទួលបានពីមន្ទីរ (នៅក្នុង D→1) ចូលក្នុង Folder 1 នៃទីតាំងបូកសរុប
- បើក File Total.xlsm ចូលទៅ Sheet Main ដើម្បីបូកសរុបគម្រោង

បូកសរុបគម្រោងថវិកា | ថ្នាក់ស្រុក | អប់រំកុមារតូច

| ពត៌មានអនុគ | |
|---|---|
| ថវិកាកម្មវិធីឆ្នាំ | ២០១៩ |
| ប្រភពមូលនិធិ | ថវិការដ្ឋ |
| រាជធានី/ខេត្ត | ខេត្តកណ្តាល |
| ក្រុង/ស្រុក/ខណ្ឌ | ស្រុកកណ្តាលស្ទឹង |
| ឈ្មោះមន្ទីរ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្តាល |
| ការិយាល័យអប់រំ/ក្រុង/ស្រុក/ខណ្ឌ | ការិយាល័យអប់រំ ស្រុកកណ្តាលស្ទឹង |
| កម្មវិធី | ១៖ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ |
| អនុកម្មវិធី | ១.១០៖ សេវាគាំទ្រការអភិវឌ្ឍការអប់រំក្នុងប្រ |
| ចង្កោមសកម្មភាព | ១.១០.០៨៖ខេត្តកណ្តាល |
| សកម្មភាព | ១.១០.០៨.១៖ការពង្រីកការអប់រំកុមារតូច |
| អនុសកម្មភាព | ១.១០.០៨.១.២៖ថវិកាដំណើរការសាលា |

បូកសរុប | Break Links

1. បញ្ចូលឆ្នាំថវិកា

2. ជ្រើសរើសខេត្ត

3. ជ្រើសរើសស្រុក

4. ជ្រើសរើស៖ ការពង្រីកការអប់រំកុមារតូច

5. ជ្រើសរើសយកថវិកាដំណើរការសាលា

6. ចុចប៊ូតុង បូកសរុប ដើម្បីសរុបគម្រោង

បូកសរុបគម្រោងថវិកា | ថ្នាក់ស្រុក | បឋមសិក្សា

Copy File ដែលសាលាបឋមសិក្សាដាច់ រួមទាំងសាលាបឋមសិក្សាដែលនៅជាមួយអនុវិទ្យាល័យ បានគ្រោងរួចចូលក្នុង Folder លេខ **2** ។ មុនពេល Copy មើលបញ្ជីថាតើសាលានោះនៅលេខរៀងទីប៉ុន្មាន រួចដូរឈ្មោះអោយស្របតាមលេខរៀងនោះដោយផ្តើមដោយអក្សរដែលបានកំណត់។

ឧទាហរណ៍៖ សម្រាប់បឋមសិក្សា

ស្រុក កណ្តាលស្ទឹង

| ល.រ | ឈ្មោះសាលាបឋមសិក្សា |
|---|---|
| 1 | សាលាបឋមសិក្សាអំពៅព្រៃ |
| 2 | សាលាបឋមសិក្សាគោក |

P1.xlsx
P2.xlsx
Total.xlsm

- ដូរឈ្មោះ File របស់សាលាបឋមសិក្សាអំពៅព្រៃទៅជា P1.xlsm រួច Copy ចូល Folder 2 នៃទីតាំងបូកសរុប
- ដូរឈ្មោះ File របស់សាលាបឋមសិក្សាគោកទៅជា P2.xlsm រួច Copy ចូល Folder 2 នៃទីតាំងបូកសរុប
- Copy File ឈ្មោះ Total.xlsm ដែលទទួលបានពីមន្ទីរ (នៅក្នុង D→2) ចូលក្នុង Folder ឈ្មោះ 2 នៃទីតាំងបូកសរុប
- បើក File Total.xlsm ចូលទៅ Sheet Main ដើម្បីបូកសរុបគម្រោង

បូកសរុបគម្រោងថវិកា | ថ្នាក់ស្រុក | បឋមសិក្សា



| ព័ត៌មានអង្គភាព... | |
|---|---|
| ថវិកាកម្មវិធីឆ្នាំ | ២០១៩ |
| ប្រភពមូលនិធិ | ថវិការដ្ឋ |
| រាជធានី/ខេត្ត | ខេត្តកណ្តាល |
| ក្រុង/ស្រុក/ខណ្ឌ | ស្រុកកណ្តាលស្ទឹង |
| ឈ្មោះមន្ទីរ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្តាល |
| ការិយាល័យអប់រំ/ក្រុង/ស្រុក/ខណ្ឌ | ការិយាល័យអប់រំ ស្រុកកណ្តាលស្ទឹង |
| កម្មវិធី | ១៖ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ |
| អនុកម្មវិធី | ១.១០៖ សេវាគាំទ្រការអភិវឌ្ឍការអប់រំក្នុងប្រ |
| ចង្កោមសកម្មភាព | ១.១០.០៨៖ខេត្តកណ្តាល |
| សកម្មភាព | ១.១០.០៨.២៖ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការ |
| អនុសកម្មភាព | ១.១០.០៨.២.២៖ថវិកាដំណើរការសាលា |

បូកសរុបគម្រោងថវិកា | ថ្នាក់ស្រុក | អនុវិទ្យាល័យ

Copy File ដែលសាលាអនុវិទ្យាល័យដាច់ រួមទាំងអនុវិទ្យាល័យដែលនៅជាមួយវិទ្យាល័យ បានគ្រោងរួចចូលក្នុង Folder លេខ 3 ។ មុនពេល Copy មើលបញ្ជីថាតើសាលានោះនៅលេខរៀងទីប៉ុន្មាន រួចដូរឈ្មោះអោយស្របតាមលេខរៀងនោះដោយផ្ដើមដោយអក្សរដែលបានកំណត់។

| ស្រុក កណ្ដាលស្ទឹង | |
|---|---|
| ល.រ | ឈ្មោះអនុវិទ្យាល័យ |
| 1 | អនុវិទ្យាល័យគោករមៀត |
| 2 | អនុវិទ្យាល័យថ្មី |
| 3 | អនុវិទ្យាល័យត្បែង |




- ដូរឈ្មោះ File របស់អនុវិទ្យាល័យគោករមៀតទៅជា S1.xlsm រួច Copy ចូល Folder 3 នៃទីតាំងបូកសរុប
- ដូរឈ្មោះ File របស់អនុវិទ្យាល័យថ្មីទៅជា S2.xlsm រួច Copy ចូល Folder 3 នៃទីតាំងបូកសរុប
- ដូរឈ្មោះ File របស់អនុវិទ្យាល័យត្បែងទៅជា S3.xlsm រួច Copy ចូល Folder 3 នៃទីតាំងបូកសរុប
- Copy File ឈ្មោះ Total.xlsm ដែលទទួលបានពីមន្ទីរ (នៅក្នុង D→3) ចូលក្នុង Folder 3 នៃទីតាំងបូកសរុប
- បើក File Total.xlsm ចូលទៅ Sheet Main ដើម្បីបូកសរុបគម្រោង

# ការបូកសរុបគម្រោងថវិការបស់គ្រឹះស្ថានសាធារណៈ



បូកសរុបគម្រោងថវិកា | *ថ្នាក់ស្រុក* | *អនុវិទ្យាល័យ*

| | |
|---|---|
| ថវិកាកម្មវិធីឆ្នាំ | ២០១៩ |
| ប្រភពមូលនិធិ | ថវិការដ្ឋ |
| រាជធានី/ខេត្ត | ខេត្តកណ្តាល |
| ក្រុង/ស្រុក/ខណ្ឌ | ស្រុកកណ្តាលស្ទឹង |
| ឈ្មោះមន្ទីរ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្តាល |
| ការិយាល័យអប់រំ/ក្រុង/ស្រុក/ខណ្ឌ | ការិយាល័យអប់រំ ស្រុកកណ្តាលស្ទឹង |
| កម្មវិធី | ១៖ការអភិវឌ្ឍការអប់ |
| អនុកម្មវិធី | ១.១០៖ សេវាគាំទ្រក |
| ចង្កោមសកម្មភាព | ១.១០.០៨៖ខេត្តកណ្តាល |
| សកម្មភាព | ១.១០.០៨.៣៖ការចូលរៀនប្រកបដោយសមធម៌ ការពង្រ |
| អនុសកម្មភាព | ១.១០.០៨.៣.២៖ថវិកាដំណើរការសាលា |

1. បញ្ចូលឆ្នាំថវិកា

2. ជ្រើសរើសខេត្ត

3. ជ្រើសរើសស្រុក

4. ជ្រើសរើស៖ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា

5. ជ្រើសរើសយកថវិកាដំណើរការសាលា

6. ចុចប៊ូតុង បូកសរុប ដើម្បីសរុបគម្រោង

បូកសរុប | Break Links

បូកសរុបគម្រោងថវិកា | ថ្នាក់ស្រុក | វិទ្យាល័យ

Copy File ដែលសាលាបឋមសិក្សាដាច់ រួមទាំងសាលាបឋមសិក្សាដែលនៅជាមួយអនុវិទ្យាល័យ បានគ្រោងរួចចូលក្នុង Folder លេខ **2** ។ មុនពេល Copy មើលបញ្ជីថាតើសាលានោះនៅលេខរៀងទីប៉ុន្មាន រួចដូរឈ្មោះអោយស្របតាមលេខរៀងនោះដោយផ្តើមដោយអក្សរដែលបានកំណត់។

ឧទាហរណ៍៖ សម្រាប់វិទ្យាល័យ

| ស្រុក កណ្តាលស្ទឹង | |
|---|---|
| ល.រ | ឈ្មោះវិទ្យាល័យ |
| 1 | វិទ្យាល័យហ៊ុនសែនកំពង់កន្ទួត |
| 2 | វិទ្យាល័យស្លែង |

- H1.xlsx
- H2.xlsx
- Total.xlsm

- ដូរឈ្មោះ File របស់វិទ្យាល័យហ៊ុនសែនកំពង់កន្ទួត ទៅជា H1.xlsm រួច Copy ចូល Folder 4 នៃទីតាំងបូកសរុប
- ដូរឈ្មោះ File របស់វិទ្យាល័យស្លែង ទៅជា H2.xlsm រួច Copy ចូល Folder 4 នៃទីតាំងបូកសរុប
- Copy File ឈ្មោះ Total.xlsm ដែលទទួលបានពីមន្ទីរ (នៅក្នុង D→4) ចូលក្នុង Folder 4 នៃទីតាំងបូកសរុប
- បើក File Total.xlsm ចូលទៅ Sheet Main ដើម្បីបូកសរុបគម្រោង

# ការបូកសរុបគម្រោងថវិការបស់គ្រឹះស្ថានសាធារណៈ



បូកសរុបគម្រោងថវិកា | *ថ្នាក់ស្រុក* | *វិទ្យាល័យ*



បូកសរុបគម្រោងថវិកា | ថ្នាក់ស្រុក | អគារធនធាន

ឧទាហរណ៍: (សម្រាប់អគារធនធាន)

| ស្រុក កណ្ដាលស្ទឹង | |
|---|---|
| ល.រ | ឈ្មោះអគារធនធាន |
| 1 | វិទ្យាល័យទេពប្រណម្យ |
| 2 | |




- ដូរឈ្មោះ File របស់វិទ្យាល័យទេពប្រណម្យ ទៅជា R1.xlsm រួច Copy ចូល Folder 5 នៃទីតាំងបូកសរុប
- Copy File ឈ្មោះ Total.xlsm ដែលទទួលបានពីមន្ទីរ (នៅក្នុង D→5) ចូលក្នុង Folder 5 នៃទីតាំងបូកសរុប
- បើក File Total.xlsm ចូលទៅ Sheet Main ដើម្បីបូកសរុបគម្រោង

# ការបូកសរុបគម្រោងថវិការបស់គ្រឹះស្ថានសាធារណៈ



បូកសរុបគម្រោងថវិកា → ថ្នាក់ស្រុក → អគារធនធាន

| ពត៌មានអន្ត | |
|---|---|
| ថវិកាកម្មវិធីឆ្នាំ | ២០១៩ |
| ប្រភពមូលនិធិ | ថវិការដ្ឋ |
| រាជធានី/ខេត្ត | ខេត្តកណ្ដាល |
| ក្រុង/ស្រុក/ខណ្ឌ | ស្រុកកណ្ដាលស្ទឹង |
| ឈ្មោះមន្ទីរ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្ដាល |
| ការិយាល័យអប់រំ/ក្រុង/ស្រុក/ខណ្ឌ | ការិយាល័យអប់រំ ស្រុកកណ្ដាលស្ទឹង |
| កម្មវិធី | ១៖ការអភិវឌ្ឍការអប់ |
| អនុកម្មវិធី | ១.១០៖ សេវាគាំទ្រ |
| ចង្កោមសកម្មភាព | ១.១០.០៨៖ខេត្តកណ្ដាល |
| សកម្មភាព | ១.១០.០៨.៣៖ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹ |
| អនុសកម្មភាព | ១.១០.០៨.៣.៦៖ថវិកាដំណើរការអគារធនធាន |

បូកសរុប | Break Links

1. បញ្ចូលឆ្នាំថវិកា

2. ជ្រើសរើសខេត្ត

3. ជ្រើសរើសស្រុក

4. ជ្រើសរើស៖ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹង គុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា

5. ជ្រើសរើសយកថវិកាដំណើរការអគារធនធាន

6. ចុចប៊ូតុង បូកសរុប ដើម្បីសរុបគម្រោង

បូកសរុបគម្រោងថវិកា | ថ្នាក់ស្រុក | វិទ្យាល័យបច្ចេកទេស

ឧទាហរណ៍: (សម្រាប់វិទ្យាល័យបច្ចេកទេស)

| ស្រុក កណ្តាលស្ទឹង | |
|---|---|
| ល.រ | ឈ្មោះវិទ្យាល័យបច្ចេកទេស |
| 1 | វិទ្យាល័យបច្ចេកទេសកណ្តាលស្ទឹង |
| 2 | |
| 3 | |




- ដូរឈ្មោះ File របស់វិទ្យាល័យបច្ចេកទេសកណ្តាលស្ទឹង ទៅជា T1.xlsm រួច Copy ចូល Folder 6 នៃទីតាំងបូកសរុប
- Copy File ឈ្មោះ Total.xlsm ដែលទទួលបានពីមន្ទីរ (នៅក្នុង D→6) ចូលក្នុង Folder 6 នៃទីតាំងបូកសរុប
- បើក File Total.xlsm ចូលទៅ Sheet Main ដើម្បីបូកសរុបគម្រោង

# ការបូកសរុបគម្រោងថវិការបស់គ្រឹះស្ថានសាធារណៈ



បូកសរុបគម្រោងថវិកា | ថ្នាក់ស្រុក | វិទ្យាល័យបច្ចេកទេស

1. បញ្ចូលឆ្នាំថវិកា

| | |
|---|---|
| ថវិកាកម្មវិធីឆ្នាំ | ២០១៩ |
| ប្រភពមូលនិធិ | ថវិការដ្ឋ |
| រាជធានី/ខេត្ត | ខេត្តកណ្ដាល |
| ក្រុង/ស្រុក/ខណ្ឌ | ស្រុកកណ្ដាលស្ទឹង |
| ឈ្មោះមន្ទីរ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្ដាល |
| ការិយាល័យអប់រំ/ក្រុង/ស្រុក/ខណ្ឌ | ការិយាល័យអប់រំ ស្រុក... |
| កម្មវិធី | ១៖ការអភិវឌ្ឍការអ... |
| អនុកម្មវិធី | ១.១០៖ សេវាគាំទ្រ... |
| ចង្កោមសកម្មភាព | ១.១០.០៨៖ខេត្តកណ្ដាល |
| សកម្មភាព | ១.១០.០៨.៦៖លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃ... |
| អនុសកម្មភាព | ១.១០.០៨.៦.២៖ថវិកាដំណើរការវិទ្យាល័យបច្ចេក... |

2. ជ្រើសរើសខេត្ត

3. ជ្រើសរើសស្រុក

4. ជ្រើសរើស៖លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស

5. ជ្រើសរើសយក៖ ថវិកាដំណើរការវិទ្យាល័យបច្ចេកទេស

6. ចុចប៊ូតុង បូកសរុប ដើម្បីសរុបគម្រោង

បូកសរុប | Break Links

6 **ការបូកសរុបគម្រោងថវិការបស់គ្រឹះស្ថានសាធារណៈ** 

## បូកសរុបគម្រោងថវិកា | *ថ្នាក់ស្រុក*

បន្ទាប់ពីបូកសរុបគម្រោងថវិការបស់សាលាគ្រប់អនុវិស័យរួចមក ការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ ត្រូវបូកសរុប គម្រោងថវិការបស់សាលាទូទាំងស្រុក និង គម្រោងថវិការបស់ខ្លួនផងដែរ។ សូមត្រប់ចាកចេញពី Folder សម្រាប់បូកសរុបតាមសាលានីមួយៗ (សូមមើលឧទាហរណ៍ខាងក្រោម)។

ឧទាហរណ៍៖ សម្រាប់ស្រុកដែលមាន
មេត្តយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ
វិទ្យាល័យ អគារធនធាន
និងវិទ្យាល័យបច្ចេកទេស

សូមបើក File Total_Schools_and_District.xlsm
សម្រាប់បូកសរុបគម្រោងទាំងអស់



## បូកសរុបគម្រោងថវិកា *ថ្នាក់ស្រុក*

ក្នុង File Total_Schools_and_District.xlsm មាន Sheet ជាច្រើនដូចជា៖

1. Master: សម្រាប់បំពេញព័ត៌មានរបស់ការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ
2. SOB_Dist_Toilet_SubAcc សម្រាប់បូកសរុបគម្រោងថវិកាទូទាំងស្រុក ទាំង SOB បង្គន់អនាម័យ អាហារូបករណ៍ និងថវិកាការិយាល័យអប់រំតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិការថវិកា

1. TotalByExp: សម្រាប់សរុបថវិកាទូទាំងស្រុក តាមប្រភេទចំណាយ
2. Toilet: សម្រាប់បូកសរុបថវិកាបង្គន់អនាម័យទូទាំងស្រុក
3. TotalDistrictBySubaccount: បង្ហាញគម្រោងថវិការបស់ស្រុក
4. TotalSOBBySubaccount: បូកសរុបគម្រោង SOB ទូទាំងស្រុក



## បូកសរុបគម្រោងថវិកា ថ្នាក់ស្រុក

ចូលទៅកាន់ Sheet Master

1. បំពេញឆ្នាំថវិកា
2. ជ្រើសរើសខេត្ត
3. ជ្រើសរើសស្រុក
4. ចុចប៊ូតុង បូកសរុប
5. ពេលបូកសរុបចប់ សូមចុចលើ ប៊ូតុង Break Link ដើម្បីផ្តាច់ Link រួចផ្ញើរ File Total_Schools_and_District.xlsm តែមួយប៉ុណ្ណោះ ទៅមន្ទីរអប់រំ យុវជន និងកីឡាដើម្បីបូកសរុបទូទាំងខេត្ត



## បូកសរុបគម្រោងថវិកា ថ្នាក់ស្រុក

ពេលបូកសរុបចប់ យើងនឹងទទួលបាន Sheet ចំនួន៨ បន្ថែមទៀត ឬតិចជាងនេះទៅតាមអនុវិស័យដែលស្រុកមាន៖

1. Total_SOB សរុបគម្រោងថវិកាទាំងអស់តាមមុខសញ្ញាចំណាយ
2. Total_SOB_1 សរុបមត្តេយ្យសិក្សា
3. Total_SOB_2 សរុបបឋមសិក្សា
4. Total_SOB_3 សរុបអនុវិទ្យាល័យ
5. Total_SOB_4 សរុបវិទ្យាល័យ
6. Total_SOB_5 សរុបមអគារធនធាន
7. Total_SOB_6 សរុបវិទ្យាល័យបច្ចេកទេស
8. Total_SCL សរុបថវិកាអាហារូបករណ៍

| TOTAL_SOB | TOTAL_SOB_1 | TOTAL_SOB_2 | TOTAL_SOB_3 | TOTAL_SOB_4 | TOTAL_SOB_5 | TOTAL_SOB_6 | TOTAL_SCL |
|---|---|---|---|---|---|---|---|

## បូកសរុបគម្រោងថវិកា › *ថ្នាក់ខេត្ត*

បន្ទាប់ពីថ្នាក់ស្រុកបូកសរុបគម្រោងចប់ ត្រូវ Copy File Total_Schools_and_District.xlsm តែមួយប៉ុណ្ណោះជូនមន្ទីរ។ បន្ទាប់ពីទទួលបានគម្រោងថវិកាពីគ្រប់ស្រុកមក មន្ទីរជាអ្នកបូកសរុបគម្រោងថវិកាទូទាំងខេត្ត។ ត្រូវទៅមើលបញ្ជីដែលបានចុះថាតើស្រុកណានៅលេខរៀងទីប៉ុន្មាន រួចដូរឈ្មោះអោយស្របតាមលេខរៀងនោះ។ ឧទាហរណ៍:

- បង្កើត Folder ថ្មី ក្នុង Folder 2019 ដាក់ឈ្មោះថា D1 រួច Copy File Total_Schools_and_District.xlsm ដែលទទួលបានពីក្រុងតាខ្មៅ (Folder 2019 ជាទីតាំងបូកសរុប)
- បង្កើត Folder ថ្មី ក្នុង Folder 2019 ដាក់ឈ្មោះថា D2 រួច Copy File Total_Schools_and_District.xlsm ដែលទទួលបានពីស្រុកកៀនស្វាយ
- Copy File ឈ្មោះ Total_SOB.xlsm ដែលទទួលបានពីមន្ទីរ (នៅក្នុង P) ចូលក្នុង Folder 2019

| ខេត្ត កណ្ដាល | |
|---|---|
| ល.រ | ឈ្មោះស្រុក |
| 1 | ក្រុងតាខ្មៅ |
| 2 | ស្រុកកៀនស្វាយ |

- D1
- D2
- Total_SOB.xlsm

## បូកសរុបគម្រោងថវិកា — *ថ្នាក់ខេត្ត*

ចំពោះ File Total_SOB_xlsm មាន Sheet ដែលមានតួនាទីក្នុងការបូកសរុបគម្រោងថវិកាដូច File Total_Schools_and_District.xlsm ដែរ ប៉ុន្តែខុសគ្នាត្រង់កម្រិតនៃការបូកសរុប។ បន្ទាប់ពីប្រមូលបានគម្រោងថវិកាតាមបណ្តាការិយាល័យអប់រំ និងដាក់លេខរៀងរួច សូមបើក File Total_SOB.xlsm រួចចូលទៅ Sheet Master៖

1. បំពេញឆ្នាំថវិកា
2. ជ្រើសរើសខេត្ត
3. ចុចប៊ូតុង បូកសរុប

បន្ទាប់ពីបូកសរុបចប់ យើងអាចពិនិត្យមើល និងបោះពុម្ពគម្រោងថវិកាតាម Sheet ផ្សេងៗបាន។



# សូមអរគុណ!